កំណាព្យ **អក្សរខ្មែរ**

វប្បធម៌ខ្មែរល្បី    រន្ទឺឥតបី    នាអតីតកាល
ប្រទេសធ្លាប់ធំ    កងទ័ពខ្លាំងក្លា    អក្សរសាស្ត្រា
ក៏ល្បាញល្បីដែរ    ។

បើមើលសីលយ័ន្ត    ពិតល្បីថាគ្រាន់    មានឫទ្ធិពូកែ
កូឡាថៃឡាវ    ប្រើអក្សរខ្មែរ    នោះទើបពូកែ
មានឫទ្ធិចេស្តា    ។

បើថ្លែងពីស្រៈ    បើមើលឱ្យជាក់    ឃើញខ្លាំងអស្ចារ្យ
សុទ្ធតែពាក្យសឹក    បញ្ចេញឫទ្យា[1]    កាប់ចាក់ប្រហារ
អ្នកសឹកតាក់តែង    ។

ស្រៈ **ា** ទាញយារ    លើកដាវប្រហារ    ទាញយ៉ាងសំរ៉ៀង
ស្រៈ **ុ** បុកជើង    រុកស្នូរលំពែង    ស្រះ **ះ** ឥតក្លែង
ហៅថារះមុខ    ។

បើសំលាប់ **ច**    អានចេញថាប់    កូនអើយចាំទុក
បើវះពោះវិញ    អានទៅថ្ងៃមុខ    **ម** យ៉ាងស្រណុក
ប ស្លាប់ទៅហើយ    ។

បើរៀនអក្សរ    ប្រកប **ក ខ**    ជ្រៅបន្តិចហើយ
គេថាផ្ទើរជើង    កាត់ផ្ទើរអ្នកអើយ    ពាក្យសឹកពិតហើយ
នេះអក្សរខ្មែរ    ។

បើពិនិត្យស្រៈ    **ı ា ិ ះ**    រឹតអស្ចារ្យដែរ
ដូចខ្សែកងទ័ព    ចេញច្បាំងពលរេហ៍    កូនអើយឃើញទេ

---

[1] អានថា រឹត ថ្យា ។

ខ្មែរសម័យនោះ ។

ា ៅ មុខគេ ៅ ដូចទំពមេ ជិះសេះអាវក្រោះ

ិ ី ឹ ឺ ទំពទង់ជ័យក្លោះ ុ ូ ួ ស្នោះ

ដូចទំពជើងទឹក ។

ឿ ៀ រាងធំ ឫកស្វែងហើយហំ ដូចមេទំពសឹក

នាសម័យដើម យកដំរីដឹក មេមេរងសឹក

ដំរីជាយាន ។

វីស្រៈនៅសល់ បើមើលឱ្យដល់ ដូចកូនទាហ៊ាន

ស្ពាយដាវស្ពាយខែល លំពែងក៏មាន គឺដូចទាហាន

ហែរក្បួនចេញច្បាំង ។

កូនអើយឃើញទេ អក្សរសាស្ត្រខ្មែរ គឺពិតជាខ្លាំង

លក្ខណៈផ្ទាល់ខ្លួន អាចឆ្លុះបញ្ចាំង ភាពជាកម្លាំង

អក្សរសាស្ត្រខ្មែរ ។

ពិតអាចចម្លង វប្បធម៌ជាតិផង មកធ្វើជាខ្មែរ

តែយ៉ាងហោចណាស់ មានសញ្ញាណខ្លួនដែរ ពិសេសខុសគេ

របស់ខេមរា ។

ស្រៈ ូ កណ្តាលប្រហោង ទូកទូរមូរផង ប្រហោងកណ្តាលដូចគ្នា

ស្រៈ ួ ស្ទុគ្រស្នាញ ដូចក្បួនសាស្ត្រា ទោះពួនផងគ្នា

ក៏សុទ្ធស្នាញស្ទុគ្រ ។

វីស្រៈ ុ វិញ ចូរកូនទន្ទេញ ច្រើនចុះច្រើនបុក

ដូចរុកជាដើម ដូចចុះចុកឆ្នុក សុទ្ធសឹងចុះបុក

ទៅខាងក្រោមពិត ។

ពាក្យប្រើស្រៈ ើ គឺច្រើនទៅលើ ដូចធ្វើរទើរជិត

ដូចឡើងលើលើស ដូចខ្មើយកើយកិត ដូចសើយទ្រើងពិត
ទៅលើដូចគ្នា ។

ហេតុអឿនពោលនេះ គ្រាន់ជាតិរិះ ចងជាកាព្យា
ជាមតិមួយ ជួយគិតគូរគ្នា កុំអ្វីតែងជា
ទ្រព្យជាតិគេនោះ ។

ខ្មែរមានទ្រព្យដែរ កុំអីរបស់គេ ខ្លួនឯងគ្មានសោះ
រៀនស្គាល់ខ្លួនសិន ខ្មែរមិនមែនងោះ បើមិនចេះស្មោះ
សាងអង្គរកើតឬ ?

តែងនៅថ្ងៃទី ៧ ខែ វិច្ឆិការ ឆ្នាំ ២០០៧[២]

តែងដោយ : មេធាវី **សុក សំអឿន** នាយកក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

---

[២] ថ្ងៃនេះអ្នកនិពន្ធបានចូលរួមការប្រជុំបូកសារុបរបាយការណ៍ពីការទប់ស្កាត់អំពើជួញដូរនៅក្រសួងមហាផ្ទៃ មាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាគណៈអធិបតី ។